ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# របាយការណ៍សិក្សាស្រាវជ្រាវ

# ស្ដីពី

# ផលជះនៃការអនុវត្តកម្មវិធី ការផ្ដល់សេវាបណ្ដុះបណ្ដាលជំនាញបន្ថែម ផ្នែកស្ទែមនៅវិទ្យាល័យធនធាន

នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ

ខែតុលា ឆ្នាំ២០២៤

# មាតិកា


**មូលន័យសង្ខេប** ........ 3

**១. សេចក្តីផ្តើម** ........ 4

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ........ 4

១.២. សំណួរស្រាវជ្រាវ ........ 5

១.៣. វត្ថុបំណងស្រាវជ្រាវ ........ 6

**២. រំលឹកទ្រឹស្តី** ........ 6

**៣. វិធីសាស្ត្រស្រាវជ្រាវ** ........ 10

៣.១. លំហសំណាក និងភាគសំណាក ........ 10

៣.១.១. លំហសំណាក ........ 10

៣.១.២. ភាគសំណាក ........ 10

៣.២. ការសាងឧបករណ៍ប្រមូលព័ត៌មាន ........ 11

៣.៣. ដំណើរការប្រមូលព័ត៌មាន ........ 11

៣.៤. ការវិភាគទិន្នន័យ ........ 11

៤.១. ការវិភាគទិន្នន័យប្រជាសាស្ត្រ ........ 12

៤.១.១. ទិន្នន័យប្រជាសាស្ត្ររបស់សិស្ស ........ 12

៤.១.២. ទិន្នន័យប្រជាសាស្ត្ររបស់អ្នកអាណាព្យាបាល ........ 14

៤.១.៣. ទិន្នន័យប្រជាសាស្ត្រគណៈគ្រប់គ្រងសាលា ........ 16

៤.១.៤. ទិន្នន័យប្រជាសាស្ត្រមន្ទីរអប់រំ យុវជន និងកីឡា និងការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង/ស្រុក/ខណ្ឌ ........ 18

៤.១.៥. ទិន្នន័យប្រជាសាស្ត្រគ្រូបណ្តុះបណ្តាលជំនាញ ........ 19

៤.២. លទ្ធផលស្រាវជ្រាវបែបបរិមាណវិស័យ ........ 19

៤.២.១. សំណួរស្រាវជ្រាវទី១ ........ 19

៤.២.២. សំណួរស្រាវជ្រាវទី២ ........ 24

៤.៣.៣. សំណួរស្រាវជ្រាវទី៣ ........ 33

**៥. ការសន្និដ្ឋាន និងអនុសាសន៍** ........ 39

**៦. ឯកសារយោង** ........ 41

**៧. ឧបសម្ព័ន្ធ** ........ 44

៧.១. កម្រងសំណួរប្រមូលព័ត៌មានសម្រាប់សិស្ស ........ 44

៧.២. កម្រងសំណួរប្រមូលព័ត៌មានសម្រាប់អ្នកអាណាព្យាបាល ........ 47

៧.៣. កម្រងសំណួរប្រមូលព័ត៌មានសម្រាប់គណៈគ្រប់គ្រងសាលា ........ 50

៧.៤. កម្រងសំណួរប្រមូលព័ត៌មានសម្រាប់មន្ទីរអប់រំ យុវជន និងកីឡា និងការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង/ស្រុក/ខណ្ឌ ........ 53

៧.៥. កម្រងសំណួរប្រមូលព័ត៌មានសម្រាប់គ្រូបណ្តុះបណ្តាលជំនាញ ........ 56

# មូលន័យសង្ខេប

ក្របខណ្ឌនៃការអនុវត្តគម្រោងអភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិទី២ កម្មវិធីបណ្តុះបណ្តាលជំនាញបន្ថែមផ្នែកស្ទែមត្រូវបាននិងកំពុងអនុវត្តនៅតាមវិទ្យាល័យធនធានទាំង២០ចាប់ពីឆ្នាំសិក្សា ២០២២-២០២៤។ លក្ខខណ្ឌតម្រូវការចាំបាច់របស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) នៃការពង្រីកការអនុវត្តកម្មវិធីនេះទៅដល់គ្រឹះស្ថានមធ្យមសិក្សាផ្សេងទៀតក្នុងក្របខណ្ឌនៃការអនុវត្តគម្រោងជំហានបន្ទាប់ការសិក្សាស្រាវជ្រាវនេះត្រូវបានធ្វើឡើងក្នុងគោលបំណងសិក្សាអំពីផលជះនៃការអនុវត្តកម្មវិធីការបណ្តុះបណ្តាលជំនាញបន្ថែមផ្នែកស្ទែម។

ការសិក្សាស្រាវជ្រាវនេះប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវតាមបែបបរិមាណវិស័យក្នុងទម្រង់នៃការសិក្សាទំនាក់ទំនងអថេរ។ លំហសំណាកគោលដៅនៃការសិក្សាស្រាវជ្រាវនេះ គឺត្រូវបានប្រមូលទិន្នន័យអ្នកពាក់ព័ន្ធរួមមានថ្នាក់ដឹកនាំមន្ទីរអប់រំ យុវជន និងកីឡា និងថ្នាក់ការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង/ស្រុក/ខណ្ឌ គណៈគ្រប់គ្រងសាលា គ្រូបណ្តុះបណ្តាល អ្នកអាណាព្យាបាល សិស្សចំណេះទូទៅចាប់ពីថ្នាក់ទី១០ដល់ទី១២ ដែលបានទទួលការបណ្តុះបណ្តាលនៅវិទ្យាល័យធនធានទាំង២០។ ការជ្រើសរើសសំណាកសិក្សាត្រូវបានប្រើប្រាស់វិធីសំណាកភាពងាយស្រួល (Convenience Sampling) ចំនួនសរុប៥៥៣នាក់សិស្សមានចំនួន ៤១០នាក់ អ្នកអាណាព្យាបាលចំនួន ៩២នាក់ គណៈគ្រប់គ្រងសាលាចំនួន ១៨នាក់ មន្ទីរអប់រំ យុវជន និងកីឡា និងការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង/ស្រុក/ខណ្ឌមានចំនួន ១៣នាក់ និងគ្រូបណ្តុះបណ្តាលជំនាញមានចំនួន ២០នាក់។ កម្រងបញ្ជីសំណួរត្រូវបានរៀបរៀងឡើងនិងធ្វើការសម្ភាសន៍ដោយផ្ទាល់ ហើយទិន្នន័យដែលប្រមូលបានត្រូវយកមកវិភាគតាមស្ថិតិពណ៌នាជាភាគរយ និងការវិភាគខ្លឹមសារ។

លទ្ធផលសិក្សាបានបង្ហាញថាការតម្រង់ទិសបណ្តុះបណ្តាលជំនាញបន្ថែមផ្នែកស្ទែមចំពោះសកម្មភាពចម្បងចំនួន៥ស្ថិតនៅក្នុងលំដាប់ខ្ពស់មកទាបគឺ សិស្សានុសិស្ស អ្នកអាណាព្យាបាល គណៈគ្រប់គ្រងសាលា មន្ទីរអប់រំ យុវជន និងកីឡា និងការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង/ស្រុក/ខណ្ឌ និងគ្រូបណ្តុះបណ្តាលជំនាញ បានវាយតម្លៃខ្ពស់លើជំនាញដែលជ្រើសរើសបណ្តុះបណ្តាលត្រូវនឹងចំណង់ចំណូលចិត្ត និងការស្រលាញ់របស់ខ្លួន ការដាក់ពាក្យស្នើសុំចូលរៀនជំនាញដោយស្ម័គ្រចិត្តនិងមិនមានការបង្ខិតបង្ខំ អ្នកអាណាព្យាបានជួយជំរុញ លើកទឹកចិត្ត ឯកភាពយល់ព្រម និងផ្តល់ឱកាសឱ្យអ្នកសិក្សាបានចូលរៀនជំនាញ ការផ្សព្វផ្សាយព័ត៌មានស្តីពីការបណ្តុះបណ្តាលជំនាញបន្ថែមផ្នែកស្ទែម សាលារៀនបានជួយជំរុញលើកទឹកចិត្ត និងផ្តល់ឱកាសឱ្យសិស្សដាក់ពាក្យចូលរៀនជំនាញ។

ដោយឡែកលទ្ធផលសិក្សានៃការវាយតម្លៃលើការសហការអនុវត្តកម្មវិធីបណ្តុះបណ្តាលជំនាញបន្ថែមផ្នែកស្ទែម ចំពោះសកម្មភាពចម្បងចំនួន ៥ខ្ពស់ជាងគេពីលំដាប់ខ្ពស់មកទាបបានបង្ហាញថា សិស្ស អ្នកអាណាព្យាបាល គណៈគ្រប់គ្រងសាលា មន្ទីរអប់រំ យុវជន និងកីឡា និងការិយាល័យអប់រំ យុវជននិងកីឡា នៃរដ្ឋបាលក្រុង/ស្រុក/ខណ្ឌ និងគ្រូបណ្តុះបណ្តាលជំនាញ បានផ្តល់ចំណាត់ថ្នាក់ចំពោះសកម្មភាពដូចជា គ្រូបណ្តុះបណ្តាលយកចិត្តទុកដាក់លើការបង្ហាត់បង្រៀន និងមើលថែចំពោះសិស្ស គ្រូបណ្តុះបណ្តាលគោរពពេលវេលាទៀងទាត់ និងទាន់ពេលក្នុងការបង្រៀន កម្មវិធីសិក្សាការបណ្តុះបណ្តាលជំនាញ

ឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ គ្រូបណ្ដុះបណ្ដាលមានចំណេះដឹងនិងសមត្ថភាពលើជំនាញឯកទេសរបស់ខ្លួន និងទីតាំងនៃការបណ្ដុះបណ្ដាលមានភាពងាយស្រួលក្នុងការធ្វើដំណើរ។

តួយ៉ាងលទ្ធផលនៃការសិក្សាល ទ្ធផលការបណ្ដុះបណ្ដាលជំនាញបន្ថែមផ្នែកស្ទែម បានចូលរួមចំណែកជួយដល់សិស្សានុសិស្សនេះបានបង្ហាញថា សិស្ស អ្នកអាណាព្យាបាល គណៈគ្រប់គ្រងសាលា មន្ទីរអប់រំ យុវជន និងកីឡា និងការិយាល័យអប់រំ យុវជននិងកីឡា នៃរដ្ឋបាលក្រុង/ស្រុក/ខណ្ឌ និងគ្រូបណ្ដុះបណ្ដាលជំនាញ បានផ្ដល់ចំណាត់ថ្នាក់ចំពោះសកម្មភាពចំនួន ៥ខ្ពស់ជាងគេពីលំដាប់ខ្ពស់មកទាបមានដូចជា រកឃើញ និងស្គាល់កាន់តែច្បាស់ពីទេពកោសល្យនិងឧបនិស្ស័យរបស់ខ្លួនបន្ទាប់ពីបានសិក្សាវគ្គនេះ ការយល់ដឹងពីមុខជំនាញដែលខ្លួនបានសិក្សា ការផ្លាស់ប្ដូរឥរិយាបថស្រឡាញ់ជំនាញដែលខ្លួនបានសិក្សា ជួយណែនាំនិងពន្យល់មិត្តភក្ដិពីការបណ្ដុះបណ្ដាលនិងអត្ថប្រយោជន៍ និងជួយបង្រៀនបន្តដល់មិត្តភក្ដិ ឬសិស្សប្អូន។

## ១. សេចក្ដីផ្ដើម

### ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

ឆ្លើយតបនឹងបរិបទសាកលភាវូបនីយកម្ម និងចរន្តនៃបដិវត្តឧស្សាហកម្ម ៤.០ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវក្របខណ្ឌគោលនយោបាយ និងផែនការយុទ្ធសាស្ត្រសំខាន់ៗប្រទាក់ក្រឡាគ្នាក្នុងកម្រិតថ្នាក់ជាតិផង និងក្នុងកម្រិតបច្ចេកទេសតាមរយៈក្រសួង ស្ថាប័ន អង្គភាពជាសេនាធិការនានាផង សំដៅរុញច្រាននាវាកម្ពុជា ឱ្យឈានឆ្ពោះទៅសម្រេចបាននូវសេចក្ដីប្រាថ្នា ក្នុងការប្រែក្លាយឋានៈរបស់កម្ពុជាឱ្យទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងទៅជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០ (រាជរដ្ឋាភិបាលកម្ពុជា, ២០១៧, ២០១៩)។

កម្ពុជា ជាប្រទេសដែលមានកំណើនប្រជាជនសកម្ម ត្រូវចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចច្រើនគួរឱ្យកត់សម្គាល់ជារៀងរាល់ឆ្នាំ។ កម្លាំងពលកម្មសកម្មទាំងនោះនឹងនៅតែមានសក្ដានុពលសកម្មភាពសេដ្ឋកិច្ចអំណោយផលដល់ការវិនិយោគនៅកម្ពុជាសម្រាប់រយៈពេល ៣០ ទៅ ៤០ ឆ្នាំខាងមុខទៀត (Bank, 2010)។ ភាគលាភផ្នែកប្រជាសាស្ត្រនេះ ជាផ្នែកមួយរួមចំណែកផ្ដល់សក្ដានុពលខ្ពស់ដល់កម្ពុជា ក្នុងការទាក់ទាញវិនិយោគិន ពីបរទេសឱ្យចូលមកបណ្ដាក់ទុនរកស៊ីជាបន្តបន្ទាប់ (រាជរដ្ឋាភិបាលកម្ពុជា, ២០១៥) ដែលបង្កើតបាននូវឱកាសការងារសម្រាប់យុវជន និងស្ត្រី ក្នុងវិស័យឧស្សាហកម្ម។ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (២០២៣) បានបង្ហាញពីសក្ដានុពលតម្រូវការធនធានមនុស្សក្នុងផ្នែកឧស្សាហកម្មកើនឡើងប្រមាណជាង ៨០ភាគរយ ក្នុងចំណោមតម្រូវការកម្លាំងពលកម្មសរុបជាង ១០ម៉ឺនកន្លែង។ លោក Gordon (2000) បានលើកឡើងថា មានការងាររាប់ពាន់កន្លែងក្នុងវិស័យបច្ចេកទេស ឧស្សាហកម្ម មិនអាចត្រូវបានផ្គត់ផ្គង់កម្លាំងពលកម្មឱ្យបានសមស្រប។ ក្នុងក្របខណ្ឌក្រសួងអប់រំ យុវជន និងកីឡា កម្ពុជា នៅមានបញ្ហាប្រឈមមួយក្នុងចំណោមបញ្ហាប្រឈមផ្សេងទៀតក្នុងអនុវិស័យអប់រំកម្រិតមធ្យមសិក្សា ដើម្បីបន្ស៊ីកម្លាំងពលកម្មជំនាញទៅនឹងលក្ខខណ្ឌតម្រូវការទីផ្សារការងារ នោះគឺការជួយដល់សិស្សកម្រិតមធ្យមសិក្សា (ទុតិយភូមិ) ឱ្យពួកគេមានសមត្ថភាព និងលទ្ធភាព គ្រប់គ្រាន់ក្នុងការត្រៀមលក្ខណៈសម្បត្តិបន្តឈានឆ្ពោះទៅការចាប់យកមុខជំនាញ នៅតាមគ្រឹះស្ថានឧត្តមសិក្សា ឬចូលទៅកាន់ទីផ្សារការងារក្នុងដំណាក់

កាលឆ្លងភូមិសិក្សា (ក្រសួងអប់រំ យុវជន និងកីឡា, ២០២១b)។ ទន្ទឹមនឹងនេះ ក្រសួងអប់រំ យុវជន និងកីឡា (២០២១b) ក៏បានគូសបញ្ជាក់ផងដែរអំពីគោលដៅធំៗទាំងបី ដែលជាវិធានការណ៍កម្រិតគោលនយោបាយក្នុងការដោះស្រាយបញ្ហាប្រឈមខាងលើនោះគឺការរួមគ្នាធ្វើយ៉ាងណាបង្កលក្ខណៈបើកទូលាយ និងពង្រីកគន្លងចំណេះដឹង របស់សិស្សកម្រិតមធ្យមសិក្សា ដើម្បីពួកគេមានលទ្ធភាពពេញលេញបន្តទៅឧត្តមសិក្សា ឬការអប់រំបច្ចេកទេស និងវិជ្ជាជីវៈ ឬចូលធ្វើការងារដែលផ្តល់ឱ្យនិយោជកនូវផលិតភាពខ្ពស់។ ការបង្កើនភាពឆ្លើយតបឱ្យកាន់តែពេញលេញនៃការអប់រំមធ្យមសិក្សា ទៅនឹងស្ថានភាពតម្រូវការទីផ្សារការងារបច្ចុប្បន្ន តាមរយៈការផ្សារភ្ជាប់នូវចំណេះដឹងមូលដ្ឋានពីសាលារៀនទៅនឹងពិភពការងារ (Amoah, 2015) គឺជាទស្សនាទានគន្លឹះក្នុងការជំរុញឱ្យគ្រប់ភាគីពាក់ព័ន្ធពិនិត្យ លទ្ធភាពរៀបចំ និងចូលរួមបង្កើតគំនិតសហគ្រិនភាព បណ្តុះភាសាបរទេស ពង្រឹងការអប់រំស្នែម ការអប់រំ បំណិនជីវិត ការតម្រង់ទិសអាជីព និងភាពជាអ្នកដឹកនាំដល់យុវជន (ក្រសួងអប់រំ យុវជន និងកីឡា, ២០២១b; រាជរដ្ឋាភិបាលកម្ពុជា, ២០១៩)។ ក្រសួងអប់រំ យុវជន និងកីឡា (២០២១a) បានដាក់ចេញនូវអន្តរាគមន៍គាំទ្រ កម្រិតបច្ចេកទេសតាមរយៈការអនុវត្តកម្មវិធីបណ្តុះបណ្តាលជំនាញបន្ថែមផ្នែកស្នែម នៅតាមគ្រឹះស្ថានមធ្យម សិក្សាសាធារណៈចាប់ពីឆ្នាំ២០១៩ ដល់២០២៤ ចំនួន២០ខេត្ត សរុបមាន២០សាលាធនធាន ក្រោមគម្រោងអភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិទី២ ដែលជាឥណទានកម្ចីពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។ កម្មវិធីនេះមានដើម្បីជានាការអនុវត្តកម្មវិធីនេះទទួលជោគជ័យ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំឯកសារណែនាំស្តីពី «ការគ្រប់គ្រងនិងដំណើរការប្រតិបត្តិការ ផ្តល់សេវាបណ្តុះបណ្តាលជំនាញបន្ថែមផ្នែកស្នែម នៅវិទ្យាល័យធនធាន» ក្នុងការណែនាំ និងផ្សព្វផ្សាយដល់គណៈគ្រប់គ្រង លោកគ្រូ អ្នកគ្រូ អ្នកពាក់ព័ន្ធនៅតាមវិទ្យាល័យធនធានអំពីយន្តការនៃការគ្រប់គ្រងអនុវត្ត ការអនុវត្ត និងកិច្ចសហការជាមួយសហគ្រាស ឬអ្នកផ្តល់សេវាបណ្តុះបណ្តាល ប្រកបដោយ ប្រសិទ្ធភាព គុណភាព និងតម្លាភាព ដោយមានការវាយតម្លៃសមត្ថភាពស្ថាប័នជាមុន លើបទពិសោធន៍និងការបណ្តុះបណ្តាលជំនាញបន្ថែមផ្នែកស្នែម។

ក្នុងក្របខណ្ឌនៃការអនុវត្តគម្រោងអភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិទី២ កម្មវិធីបណ្តុះបណ្តាលជំនាញបន្ថែមផ្នែកស្នែម ត្រូវបាននិងកំពុងអនុវត្តយ៉ាងផុលផុស នៅតាមវិទ្យាល័យធនធានទាំង ២០ ចាប់ពី ឆ្នាំសិក្សា២០២២-២០២៤។ ដើម្បីជាមូលដ្ឋាននៃការពង្រីកការអនុវត្តកម្មវិធីនេះទៅ ដល់គ្រឹះស្ថានមធ្យមសិក្សាផ្សេងទៀត ក្នុងក្របខណ្ឌនៃការអនុវត្តគម្រោងបន្ទាប់ ការសិក្សាស្រាវជ្រាវអំពីផលជះនៃកម្មវិធីបណ្តុះបណ្តាលជំនាញបន្ថែមផ្នែកស្នែម ជាលក្ខខណ្ឌតម្រូវការចាំបាច់របស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។ ការសិក្សាស្រាវជ្រាវជាបន្ទាន់មួយ ត្រូវបានគម្រោងនិងភាគីពាក់ព័ន្ធចាត់ទុកថាជាការចាំបាច់ ដែលនឹងត្រូវធ្វើឡើងដោយនាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ ជាអង្គភាពប្រតិបត្តិករលើការងារនេះ។

## ១.២. សំណួរស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ត្រូវបានលើកយកសំណួរស្រាវជ្រាវសំខាន់ៗចំនួន០៣ ដើម្បីសិក្សារកឱ្យឃើញនូវផលជះជាវិជ្ជមានចេញពីការអនុវត្តកម្មវិធីបណ្តុះបណ្តាលជំនាញបន្ថែមផ្នែកស្នែម កម្រិតមធ្យមសិក្សាក្នុងប្រទេសកម្ពុជា។

១ តើការតម្រង់ទិសការបណ្តុះបណ្តាលជំនាញមានលក្ខណៈដូចម្តេចខ្លះ?

២ តើការអនុវត្តកម្មវិធីការបណ្តុះបណ្តាលជំនាញមានលក្ខណៈដូចម្តេចខ្លះ?

៣ តើលទ្ធផលនៃការបណ្តុះបណ្តាលជំនាញបន្ថែមផ្នែកស្វែម បានរួមចំណែកជួយដល់សិស្សានុសិស្សដូចម្តេចខ្លះ?

### ១.៣. វត្ថុបំណងស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះត្រូវបានធ្វើឡើងក្នុងគោលបំណងសិក្សាពីផលជះចេញពីការអនុវត្តកម្មវិធីបណ្តុះបណ្តាលជំនាញបន្ថែមផ្នែកស្វែម កម្រិតមធ្យមសិក្សា ក្នុងប្រទេសកម្ពុជា។

១ សិក្សាពីការផ្តល់សេវាតម្រង់ទិសការបណ្តុះបណ្តាលជំនាញមុនចាប់ផ្តើមអនុវត្តកម្មវិធី

២ សិក្សាពីប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីការបណ្តុះបណ្តាលជំនាញ

៣ សិក្សាពីផលជះនៃការបណ្តុះបណ្តាលជំនាញបន្ថែមផ្នែកស្វែម ចំពោះសិស្សានុសិស្ស

## ២. រំលឹកទ្រឹស្តី

កម្មវិធីបណ្តុះបណ្តាលជំនាញបន្ថែមផ្នែកស្វែម ជាកម្មវិធីដ៏មានសារៈសំខាន់ក្នុងការអភិវឌ្ឍមនុស្សជាពិសេសក្នុងដំណាក់កាលវ័យជំទង់ (Leonard R Mghweno, 2014)។ ដំណាក់កាលវ័យជំទង់ត្រូវបានកំណត់ដោយការលូតលាស់ និងការផ្លាស់ប្តូរយ៉ាងឆាប់រហ័សផ្នែកៈ រាងកាយ សង្គម ខាងវិញ្ញាណ សីលធម៌ និងបញ្ញា។ ក្មេងជំទង់ភាគច្រើនស្ថិតនៅក្នុងសាលាមធ្យមសិក្សា ដែលទាមទារជាចាំបាច់នូវការផ្តល់សេវាគាំទ្រដល់ពួកគេឱ្យបានពេញលេញ។ ផ្អែកតាមលោក Bark(2003) បណ្តុះបណ្តាលជំនាញបន្ថែមផ្នែកស្វែម គឺជាជំនួយផ្នែកជំនាញបច្ចេកទេស ដែលត្រូវបានផ្តល់ដោយគ្រូបណ្តុះបណ្តាលតាមទីតាំងបណ្តុះបណ្តាល ដើម្បីជួយដល់យុវជនវ័យជំទង់ក្នុងការគ្រប់គ្រងចិត្តគំនិត សកម្មភាពនានា និងការធ្វើសេចក្តីសម្រេចចិត្តផ្សេងៗបានល្អប្រសើរ។ ផ្អែកលើនិយមន័យរបស់អង្គការសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងការអភិវឌ្ឍ (OEDC) កម្មវិធីបណ្តុះបណ្តាលជំនាញបន្ថែមផ្នែកស្វែម ត្រូវបានទទួលស្គាល់ជាសកល រួមទាំងប្រទេសដែលមានចំណូលទាប ចំណូលមធ្យម និងចំណូលខ្ពស់ ដូចខាងក្រោម៖

*ការអនុវត្តកម្មវិធីសិក្សាជំនាញបន្ថែមផ្នែកស្វែម ត្រូវផ្តោតលើការអនុវត្តជាក់ស្តែងច្រើនជាងបទបង្ហាញក្នុងថ្នាក់ (ទ្រឹស្តីយ៉ាងច្រើន៣០% និងប្រតិបត្តិយ៉ាងតិច៧០%) រហូតដល់មានសមត្ថភាព ឆ្លើយតបទៅនឹងលក្ខខណ្ឌបានកំណត់ក្នុងកម្មវិធី ដើម្បីធានាឱ្យសិស្សទទួលបាននូវសមត្ថភាពជំនាញជាក់លាក់សម្រាប់លើកកម្ពស់ជីវភាពរស់នៅ និងជំរុញទឹកចិត្តបន្តការសិក្សាជំនាញបន្ថែមផ្នែកស្វែមនៅឧត្តមសិក្សា។ ការសិក្សាទ្រឹស្តី ត្រូវផ្សារភ្ជាប់ទៅនឹងការអនុវត្តជាក់ស្តែងក្នុងបន្ទប់ពិសោធន៍ បន្ទប់ប្រតិបត្តិ រោងជាង កសិដ្ឋាន ការដ្ឋាន ឬកន្លែងប្រកបអាជីវកម្មផ្ទាល់របស់គ្រូបណ្តុះបណ្តាល ដោយផ្សារភ្ជាប់ខ្លឹមសារមេរៀនទៅនឹងការប្រតិបត្តិ ឬជីវភាពរស់នៅប្រចាំថ្ងៃ។*

ការបណ្តុះបណ្តាលជំនាញបន្ថែមផ្នែកស្វែម ក៏អាចនិយាយមួយបែបទៀតបានថា ជាកម្មវិធីគាំទ្រដល់ការអនុវត្ត នូវអន្តរសកម្មភាព និងតម្រង់ទិសគោលដៅសិស្សានុសិស្ស ព្រមទាំងជំរុញឱ្យមានការរីកចម្រើន និងការអភិវឌ្ឍផ្ទាល់ខ្លួន។ បណ្តុះបណ្តាលជំនាញបន្ថែមផ្នែកស្វែម ចូលរួមលើកកម្ពស់សមធម៌ សមភាព

ទប់ស្កាត់អត្រាបោះបង់ការសិក្សារបស់សិស្សានុសិស្ស លើកកម្ពស់ការអភិវឌ្ឍជំនាញការស្គាល់ខ្លួនឯង ការស្វែងយល់ពីពិភពការងារ ការរៀបចំខ្លួនចាប់យកជម្រើសនៃការសិក្សា ការចូលទៅក្នុងពិភពការងារ ប្រកបដោយប្រសិទ្ធភាព ផលិតភាព និងសុខដុមនីយកម្មវិជ្ជាជីវៈ។

នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ (២០២២) កម្មវិធីបណ្តុះបណ្តាលជំនាញបន្ថែមផ្នែកស្នែម ត្រូវបាន រៀបចំឡើងដើម្បីដាក់ឱ្យអនុវត្តនៅកម្រិតសាលារៀន តាមរយៈគណៈគ្រប់គ្រងតាមសាលារៀន ដោយផ្អែក លើគោលការណ៍សំខាន់ចំនួន៤គឺៈ ១)ការបណ្តុះបណ្តាល គឺជាសកម្មភាពសម្របសម្រួលការរៀនរបស់ សិស្សដើម្បីឱ្យពួកគេទទួលបាន វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ដោយប្រើប្រាស់វិធីសាស្ត្រ ចម្រុះស្របតាមស្ថានភាពអ្នកសិក្សា។ ២)ការបណ្តុះបណ្តាល គឺជាសកម្មភាពជួយ និងលើកទឹកចិត្តអ្នក សិក្សាឱ្យចេះរបៀបរៀនដោយខ្លួនឯងយ៉ាងសកម្ម មានប្រសិទ្ធភាព និងទទួលខុសត្រូវ ដើម្បីស្វែងយល់ ធ្វើវិចារ សហការ អង្កេត និងការអនុវត្តចំណេះដឹងសម្រាប់ការសិក្សា និងការរស់នៅប្រចាំថ្ងៃ។ ៣)ការបណ្តុះ បណ្តាលត្រូវបន្តពង្រឹង និងពង្រីកចំណេះដឹង បទពិសោធន៍ ទេពកោសល្យ និងចំណង់ចំណូលចិត្តរបស់ សិស្ស ដើម្បីឱ្យពួកគេស្រលាញ់ និងផ្តល់តម្លៃដល់ការសិក្សាជំនាញបន្ថែមផ្នែកស្នែម និងត្រូវផ្តោតសំខាន់លើ ការប្រតិបត្តិជាក់ស្តែងតាមជំនាញនីមួយៗ។ ៤)ការបណ្តុះបណ្តាលត្រូវតែផ្សារភ្ជាប់ទៅនឹងបរិស្ថានជុំវិញតាម រយៈការប្រើប្រាស់វិធីសាស្ត្រ និងសម្ភារឧបទេស រួមទាំងបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍សម្បូរបែប។ ដោយផ្អែកលើគោលការណ៍ទាំង៤ខាងលើ ធ្វើឱ្យសម្រេចគោលដៅសំខាន់គឺយុវជនម្នាក់ មានជំនាញមួយ យ៉ាងតិច ដើម្បីពួកគេអាចធ្វើសមាហរណកម្មខ្លួនទៅ ក្នុងស្ថានភាពជម្រើសនៃការអប់រំបន្ត និងអាជីពមុខរបរ ប្រកបដោយទំនុកចិត្ត ការប្តេជ្ញាចិត្ត ជំនឿ គុណតម្លៃ និងគុណធម៌ក្នុងជីវិត។

ក្រសួងអប់រំ យុវជន និងកីឡា (២០២២) បានដាក់ចេញនូវយន្តការណែនាំបច្ចេកទេសក្នុងការអនុវត្ត កម្មវិធីបណ្តុះបណ្តាលជំនាញបន្ថែមផ្នែកស្នែម នៅកម្រិតមធ្យមសិក្សាទុតិយភូមិ ដោយតម្រូវឱ្យគណៈ គ្រប់គ្រងសាលាធនធានត្រូវអនុវត្តការងារស្នូលសំខាន់ៗចំនួន៣៖ *មុនពេលចាប់ផ្តើមដំណើរការវគ្គ* គ្រប់គ្រង សាលាត្រូវរៀបចំឧបករណ៍ជ្រើសរើសជំនាញប្រមូលទិន្នន័យមុខជំនាញពីសិស្ស គ្រូ និងសហគមន៍ បូកសរុប និងវិភាគទិន្នន័យដែលប្រមូលបានកំណត់អាទិភាពប្រាំជំនាញយ៉ាងតិច ទៅតាមលំដាប់លំដោយដែលបាន ជ្រើសរើសច្រើនជាងគេរបៀបកំណត់ជំនាញតាមអាទិភាព រៀបចំរបាយការណ៍ជ្រើសរើសជំនាញ ស្វែងរក ទីតាំង និងគ្រូបណ្តុះបណ្តាលជំនាញ ក្នុងករណីមិនមានគ្រូបណ្តុះបណ្តាលនៅក្នុងតំបន់ គណៈកម្មការអាច ផ្តល់បន្ទប់ ទីធ្លា និងសម្ភារចាំបាច់សម្រាប់ការងារប្រតិបត្តិក្នុងពេលបណ្តុះបណ្តាល (តាមលទ្ធភាពជាក់ ស្តែងរបស់សាលាដែលអាចផ្តល់ជូន ដោយមានការឯកភាពពីគណៈកម្មការ សហគមន៍ បុគ្គលិកក្នុងវិទ្យា ល័យសាមី) ជួយសម្របសម្រួលជាមួយគ្រូបណ្តុះបណ្តាល ដើម្បីរៀបចំកម្មវិធីសិក្សា និងកាលវិភាគទៅ តាមមុខជំនាញនីមួយៗ ប្រកាសឱ្យសិស្សដាក់ពាក្យជ្រើសរើសជំនាញដែលបានកំណត់អាទិភាពជំនាញ ជ្រើសរើសបេក្ខជនដែលដាក់ពាក្យនិងកំណត់ចំនួនដោយផ្អែកតាមលក្ខខណ្ឌនៃការជ្រើសរើស រៀបចំបញ្ជី ឈ្មោះសិស្សតាមវគ្គ រៀបចំបូកសរុបផែនការចំណាយប្រចាំឆ្នាំបន្ទាប់ពីទទួលផែនការថវិកាពីគ្រូបណ្តុះ បណ្តាលតាមវគ្គនីមួយៗ រៀបចំបូកសរុបគម្រោងចំណាយលម្អិតបន្ទាប់ពីទទួលបានគម្រោងចំណាយ លម្អិតពីគ្រូបណ្តុះបណ្តាលតាមវគ្គនីមួយៗ គ្រោង និងពិនិត្យថវិកាចំណាយលម្អិត ពាក្យស្នើសុំថវិកា បណ្តុះបណ្តាលប្រកបដោយប្រសិទ្ធភាពខ្ពស់ តម្លាភាព និងគណនេយ្យភាព ពិនិត្យ និងផ្ទៀងផ្ទាត់

វិក្កយបត្រទូទាត់៣០%តាមវគ្គតាមជំនាញ និងចុះហត្ថលេខាលើកិច្ចសន្យាផ្តល់សេវាបណ្តុះបណ្តាលជាមួយគ្រូបណ្តុះបណ្តាលដោយមានការទទួលស្គាល់ពីគណៈគ្រប់គ្រងមន្ទីរ។ កំឡុងពេលដំណើរការវគ្គ គណៈគ្រប់គ្រងសាលាធនធានត្រូវរៀបចំផែនការចុះពិនិត្យតាមដានការបណ្តុះបណ្តាលតាមវគ្គ ពិនិត្យតាមដាន វាយតម្លៃវគ្គបណ្តុះបណ្តាល និងរៀបចំរបាយការណ៍ ផ្អែកលើលទ្ធផលជូនមន្ទីរ និងក្រសួងអប់រំ យុវជន និងកីឡា(នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ)តាមការកំណត់ ពិនិត្យ និងឯកភាពលើតេស្ត (ការវាយតម្លៃវឌ្ឍនភាពសមត្ថភាពនិងជំនាញរបស់សិក្ខាកាម) ករណីមានតម្រូវការសិស្សចំម៉ោងបណ្តុះបណ្តាលគណៈគ្រប់គ្រងសាលាត្រូវជូនដំណឹងទៅអ្នកបណ្តុះបណ្តាលជាមុន។ ពេលបញ្ចប់ដំណើរការវគ្គ គណៈគ្រប់គ្រងសាលាធនធានត្រូវពិនិត្យ និងឯកភាពលើតេស្តបញ្ចប់វគ្គ វាយតម្លៃសមត្ថភាពអ្នកសិក្សា និងរក្សាទុកសំណៅឯកសារតេស្ត លទ្ធផលសិក្សារបស់សិស្ស ពិនិត្យ និងផ្ទៀងផ្ទាត់វិក្កយបត្រទូទាត់ ៧០% គិតទៅតាមចំនួនអ្នកសិក្សាដែលមានក្នុងបញ្ជីឈ្មោះប្រឡងបញ្ចប់វគ្គ ពិនិត្យ និងរៀបចំបូកសរុបរបាយការណ៍បញ្ចប់វគ្គដែលទទួលបានពីគ្រូបណ្តុះបណ្តាលតាមជំនាញនីមួយៗ សម្របសម្រួលលើការរៀបចំវិញ្ញាបនបត្របញ្ជាក់ការសិក្សាជូនអ្នកសិក្សា ដែលបញ្ចប់វគ្គបណ្តុះបណ្តាលដោយជោគជ័យ និងមុននឹងចែកវិញ្ញាបនបត្រដល់សិស្សត្រូវស្នើនវិញ្ញាបនបត្រគ្រប់ជំនាញ ផ្ញើមកនាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ បន្ទាប់ពីបានឯកភាពពីមន្ទីរអប់រំ យុវជន និងកីឡា។

ក្នុងក្របខណ្ឌនៃការអនុវត្តគម្រោងអភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិទី២ វិទ្យាល័យធនធានទាំង២០ ត្រូវបានដល់ ហិរញ្ញប្បទានគម្រោងចំនួន ៤០លានរៀលក្នុងមួយវិទ្យាល័យ ក្នុងមួយឆ្នាំសិក្សាបម្រើឱ្យការចំណាយលើការអនុវត្តកម្មវិធីបណ្តុះបណ្តាលជំនាញបន្ថែមផ្នែកស្នែម និងសកម្មភាពភាពជាដៃគូរវាងសាលារៀន និងសហគមន៍មូលដ្ឋាន ដែលថវិកានេះត្រូវផ្តល់ដល់គ្រូបណ្តុះបណ្តាលផ្ទាល់ដែលមានពីរលើក លើកទី១ មុនដំណើរការបណ្តុះបណ្តាល ចំនួន៣០%នៃថ្លៃបណ្តុះបណ្តាលសរុប និងលើកទី២ បន្ទាប់ពីបញ្ចប់ការបណ្តុះបណ្តាល ចំនួន៧០% នៃថ្លៃបណ្តុះបណ្តាលសរុប។ ដែលមានសកម្មភាពការងារបណ្តុះបណ្តាលជំនាញទាំងអស់ចំនួន ២៤ជំនាញ។ ជំនាញទាំងនោះ មានជាអាទិ៍៖ ១)ប្រព័ន្ធបណ្តាញ Computer Network ២)រចនាក្រាហ្វិកGrapihc Design ៣)កាត់តរូបភាព Photshop ៤)សរសេរកូដ Coding ៥)គ្រប់គ្រងទិន្នន័យ Microsoft Access Database ៦)តម្លើងបណ្តាញខ្សែភ្លើងក្នុងអគារ Install electrical network in building ៧)តម្លើង និងជួសជុលម៉ាស៊ីនត្រជាក់ Maintenance, and install air conditioner ៨)ជួសជុលកុំព្យូទ័រ Computer maintenance ៩)ជួសជុលឧបករណ៍អេឡិចត្រូនិក Electronic tools maintenance ១០)អេឡិចត្រូនិក និងកម្មវិធីមនុស្សយន្ត Electronics and robotics ១១)ជួសជុលម៉ាស៊ីនខ្នាតធំ(រថយន្ត ...) Large machine repair (cars ...) ១២)ជួសជុលម៉ាស៊ីនខ្នាតតូច(ម៉ូតូ ម៉ូទ័រ ...) Small machine repair (motorcycles, otors ...) ១៣)ក្រឡឹង (ឈើ ដែក ...) Lathe skills (steel, wood) ១៤)បង្កាត់ពូជសត្វ Animal breeding ១៥)ចិញ្ចឹមសត្វ Animal raising ១៦)ការបង្កាត់ពូជ និងបច្ចេកទេសចិញ្ចឹមវារីសត្វ Breeding and aquaculture techniques ១៦)បង្កាត់ពូជរុក្ខជាតិ Plant breeding ១៨)បន្លែឬរុក្ខជាតិ Vegetable or plant growing ១៩)ចម្អិនអាហារ Cooking ២០)កែច្នៃសាច់សត្វ Meat processing ២១)កែច្នៃបន្លែ ផ្លែឈើ Fruit and vegetable processing ២២)កែច្នៃផលិតផលវារីសត្វ

Processing of aquatic products ២៣)ជាងកំបោរ Laying bricks and plastering និង២៤) ជំនាញតម្លើងគ្រឿងសង្ហារឹម Furniture installation នៅក្នុងជំនាញទាំងអស់ខាងលើនេះ មានចំនួន១៨ ជំនាញដែលបានបណ្ដុះបណ្ដាលពីឆ្នាំ២០២២-២០២៤។

យន្តការបច្ចេកទេសកម្រិតសាលារៀននេះ ត្រូវទទួលបន្ទុកអនុវត្តការបណ្ដុះបណ្ដាលដោយ សកលវិទ្យាល័យ វិទ្យាស្ថាន មជ្ឈមណ្ឌល សហគមន៍ និងវិស័យឯកជន ដែលមានទីតាំង សម្ភារៈ និងគ្រូ ដែលត្រូវជ្រើសរើសដោយគណៈកម្មការ ដោយកំណត់ពេលវេលា និងម៉ោងសិក្សាសម្រាប់មុខជំនាញ នីមួយៗ ត្រូវរៀបចំដោយមានការឯកភាពគ្នារវាងសាលារៀន និងអ្នកផ្ដល់សេវាបណ្ដុះបណ្ដាល។ សាលារៀន និងអ្នកផ្ដល់សេវាបណ្ដុះបណ្ដាលអាចរៀបចំម៉ោងសិក្សាបន្ថែមច្រើនជាងម៉ោងសិក្សាតាមការណែនាំ ដែល មានចែងក្នុងកម្មវិធីសិក្សានេះ ដោយយោងទៅតាមតម្រូវការជាក់ស្ដែងរបស់អ្នកសិក្សា និងស្ថានភាពនៃអ្នក ផ្ដល់សេវាបណ្ដុះបណ្ដាល ដើម្បីឈានសម្រេចគោលដៅបណ្ដុះបណ្ដាលជំនាញ។ ក្របខ័ណ្ឌពេលវេលានិង កម្មវិធីសិក្សាជំនាញបន្ថែមផ្នែកស្នែមមាន៖ ១) ជំនាញសិក្សារយៈពេល ៣ខែ ចាប់ពី ៤៥-៥០ម៉ោង ស្មើ ២ក្រេឌីត។ ២)ជំនាញសិក្សារយៈពេល ៦ខែ ចាប់ពី ៩០-១០០ម៉ោង ស្មើ ៤ក្រេឌីត។ ៣)ជំនាញ សិក្សារយៈពេល ៩ខែ ចាប់ពី ១៣៥-១៥០ម៉ោង ស្មើ ៦ក្រេឌីត។ ៤)ជំនាញសិក្សារយៈពេល ១២ខែ ចាប់ ពី ១៨០-២០០ម៉ោង ស្មើ ៨ក្រេឌីត។ ជាការពិត គ្រូបណ្ដុះបណ្ដាល អាចបំពេញតួនាទីភារកិច្ចដ៏សំខាន់ របស់ខ្លួនឱ្យទទួលបានលទ្ធផលល្អប្រសើរទៅបាន គឺអាស្រ័យមួយផ្នែកចេញអំពីភាពជឿជាក់ និងទំនុកចិត្ត ផ្ទាល់ខ្លួន។ ការយល់ឃើញប្រសិទ្ធភាពការងារខ្លួនឯង បានផ្ដល់មូលដ្ឋានដល់គ្រូបណ្ដុះបណ្ដាលក្នុងការ ណែនាំដល់សិស្សឱ្យពិចារណាយ៉ាងហ្មត់ចត់ លើជីវិតការងាររបស់ពួកគេ និងថ្លឹងថ្លែងជ្រើសរើសនូវការងារ ណាដែលពេញចិត្ត ឬមិនពេញចិត្ត (Albert Bandura, 2001)។ ភាពជឿជាក់លើសមត្ថភាពខ្លួនឯង ត្រូវ បានគេរកឃើញថា វាជាកម្លាំងចលករមួយដ៏មាន សក្ដានុពលជំរុញប្រសិទ្ធភាពនៃការសម្រេចចិត្តរបស់ បុគ្គលបានច្បាស់លាស់ ព្រមទាំងកំណត់នូវការប្ដេជ្ញា ចិត្តមុតមាំក្នុងការអនុវត្តការងារអ្វីមួយបានពេញលេញ និងទទួលបានជោគជ័យ (Lia D. Falco, 2019)។ ក្នុងវិជ្ជាជីវៈជាគ្រូបណ្ដុះបណ្ដាល ជំនឿជាក់លើខ្លួនឯង នេះ មានឥទ្ធិពលលើសេចក្ដីប្រាថ្នា និងការប្ដេជ្ញា ចិត្តមុះមុតទៅលើគុណភាពនៃការវិភាគ និងការគិតជាយុទ្ធ សាស្ត្រ កម្រិតនៃការលើកទឹកចិត្ត និងការតស៊ូក្នុងការប្រឈមមុខនឹងការលំបាកក្នុងដំណើរការអនុវត្តកម្មវិធី ការងារប្រចាំថ្ងៃ ក៏ដូចជាបញ្ហាប្រឈមផ្សេងៗដែល កើតមានឡើងក្នុងជីវិត (Betz, 2000; Nancy E. Betz, 1997)។ សិល្បៈនៃការចូលរួម និងការបង្កើតភាពជាដៃគូរវាងសាលារៀន និងសហគមន៍មូលដ្ឋាន ក៏ត្រូវបាន គេមើលឃើញផងដែរថា ជាទិដ្ឋភាពដ៏សំខាន់ក្នុងការរួមចំណែកដល់សមិទ្ធផលការងាររបស់គ្រូបណ្ដុះ បណ្ដាល ឱ្យទទួលបានប្រសិទ្ធផលគួរជាទីគាប់ចិត្តក្នុងអាជីពរបស់ខ្លួន (Bryan, 2003)។ Dedmond (1991) បានលើកឡើងថា សិស្សានុសិស្ស នឹងកាន់តែមានមូលដ្ឋានរឹងមាំជាងមុនក្នុងការសម្រេចចិត្ត ជ្រើសរើសអាជីពការងារនាថ្ងៃអនាគត ប្រសិនពួកគេទទួលបានឱកាសសមស្របក្នុងការសិក្សាស្វែងយល់ អំពីស្ថានភាពជាក់ស្ដែងនៃការធ្វើការងារនៅតាមស្ថាប័នបំពេញការងារដែលនឹងកើតឡើងតាមរយៈកិច្ច សហការក្នុងភាពជាដៃគូរវាងសាលារៀននិងសហគមន៍មូលដ្ឋាន។ ជាការពិតភាពជាដៃគូរវាងសាលា រៀន និងសហគមន៍មូលដ្ឋាន ជាច្រកទ្វារនាំសិស្សទៅកាន់ពិតពការងារមួយដែលកាន់តែផ្ដល់ឱ្យពួកគេនូវ ភាពប្រាកដប្រជា។ គ្រូបណ្ដុះបណ្ដាល ត្រូវបង្កើតយុទ្ធសាស្ត្រក្នុងការពង្រីកទំនាក់ទំនងរវាងសាលារៀន

និងភាគីពាក់ព័ន្ធនៅខាងក្រៅសាលារៀន ដើម្បីបំពេញតម្រូវការសិស្ស ក៏ដូចជាតម្រូវការសហគមន៍ផងដែរ (Taylor & Adelman, 2000)។ Dedmond (1991) បានផ្ដល់យោបល់ថា តួនាទីរបស់គ្រូបណ្ដុះបណ្ដាលតាមសាលារៀន គឺជាអ្នកសម្របសម្រួលភាពជាដៃគូរវាងសាលារៀនជាមួយមាតាបិតាសិស្ស និងសហគមន៍មូលដ្ឋានរួមមាន ក្រុមហ៊ុនសហគ្រាស ឧស្សាហកម្ម ស្ថាប័នការងារ អាជីវកម្មផ្សេងៗ គ្រឹះស្ថានផ្ដល់ការអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងឧត្ដមសិក្សា។ ជាមួយគ្នា ក្នុងបរិបទនៃការបំពេញការងារនៅកម្ពុជា គ្រូបណ្ដុះបណ្ដាល គឺជាតួអង្គសំខាន់ក្នុងការសម្របសម្រួលការងារបង្កើតភាពជាដៃគូរវាងសាលារៀន និងសហគមន៍មូលដ្ឋានរបស់ខ្លួន។ នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ (២០២១) បានបង្កើតឯកសារណែនាំស្ដីពីការគ្រប់គ្រង និងដំណើរការប្រតិបត្តិការផ្ដល់សេវាបណ្ដុះបណ្ដាលជំនាញបន្ថែមផ្នែកស្នែម នៅវិទ្យាល័យធនធាន។ ផ្ដើមចេញពីកម្មវិធីបណ្ដុះបណ្ដាលនេះធ្វើឱ្យមានជំនួបរវាងសាលារៀន ជាមួយអ្នកផ្ដល់សេវាបណ្ដុះបណ្ដាលក្នុងសហគមន៍មូលដ្ឋាន ដើម្បីពិភាក្សាពិនិត្យលទ្ធភាពស្វែងរកកិច្ចសហការក្នុងការអនុវត្តកម្មវិធីឱ្យទទួលបានលទ្ធផលល្អ។ បន្ថែមពីនេះ នៅមានកម្មវិធីដឹកនាំសិស្សចុះកម្មសិក្សាដល់ទីតាំងជាក់ស្ដែងនៃក្រុមហ៊ុន សហគ្រាស ដើម្បីសិក្សាស្វែងយល់លម្អិតពីរូបភាពការងារជាក់ស្ដែង។

## ៣. វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ នឹងត្រូវប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវតាមបែបបរិមាណក្នុងទម្រង់នៃការសិក្សាពីទំនាក់ទំនងអថេរ។ ជាទូទៅការស្រាវជ្រាវក្នុងទម្រង់សិក្សាពីទំនាក់ទំនងអថេរត្រូវបានធ្វើឡើងដើម្បីស្វែងរកពីទំនាក់ទំនងគ្នា ក្នុងចំណោមអថេរដែលនឹងត្រូវលើកយកមកសិក្សា និងពិនិត្យមើលអំពីកម្រិតឥទ្ធិពលរបស់អថេរមួយទៅលើអថេរមួយទៀត (Creswell, 2014; Creswell, 2018)។ ដើម្បីឆ្លើយតបទៅ នឹងសំណួរស្រាវជ្រាវខាងលើ អ្នកសិក្សាស្រាវបានឌីហ្សាញការសិក្សាស្រាវជ្រាវដូចខាងក្រោម៖

### ៣.១. លំហសំណាក និងភាគសំណាក

#### ៣.១.១. លំហសំណាក

លំហសំណាកដែលប្រើក្នុងការសិក្សាស្រាវជ្រាវនេះ គឺជាបានមកពី២០ខេត្ត គោលដៅ មានសមាសភាពដូចជា៖ មន្ទីរអប់រំ យុវជន និងកីឡា និងការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង/ស្រុក/ខណ្ឌ គណៈគ្រប់គ្រងសាលា គ្រូបណ្ដុះបណ្ដាល អ្នកអាណាព្យាបាល សិស្សចំណោះទូទៅដែលកំពុងសិក្សាចាប់ពីថ្នាក់ទី១០ ដល់ថ្នាក់ទី១២ និងសិស្សអប់រំបច្ចេកទេស ថ្នាក់ឆ្នាំទី១ ទី២ និងថ្នាក់ឆ្នាំទី៣ នៃវិទ្យាល័យធនធានទាំង២០ ក្នុងឆ្នាំ២០២២-២០២៣។

#### ៣.១.២. ភាគសំណាក

ការជ្រើសរើសសំណាកដើម្បីប្រមូលទិន្នន័យ គឺមានសារៈសំខាន់ណាស់ក្នុងការសិក្សាស្រាវជ្រាវតាមបែបបរិមាណវិស័យ។ ជាទូទៅ ការឌីហ្សាញភាគសំណាកក្នុងការសិក្សាស្រាវជ្រាវតាមបែបបរិមាណគឺត្រូវភ្ជាប់មកជាមួយនូវគុណលក្ខណៈរបស់ភាគសំណាកចំនួនសំណាក និងវិធីសាស្ត្រជ្រើសរើសសំណាកឱ្យបានច្បាស់លាស់ដើម្បីទទួលបានភាពជាតំណាងតាមលក្ខណៈវិទ្យាសាស្ត្រ (Antonius, 2003)។

ក្នុងការសិក្សាស្រាវជ្រាវនេះ អ្នកសិក្សាបានជ្រើសរើសសំណាកដើម្បីប្រមូលទិន្នន័យដោយប្រើវិធីសាស្ត្រតាមបែបងាយស្រួល (Convenience Sampling) ដើម្បីជ្រើសរើសអ្នកចូលរួមឆ្លើយកម្រងសំណួរប្រមូលទិន្នន័យ ចេញពីវិទ្យាល័យធនធានទាំង២០។ ទិន្នន័យដែលទទួលបានតាមរយៈការបំពេញកម្រងសំណួរប្រមូលព័ត៌មានតាមរយៈការបំពេញកម្រងសំណួរដោយផ្ទាល់មានអ្នកចូលរួមសរុបចំនួន ៥៥៣នាក់ ស្រីចំនួន ២៤៧នាក់ សិស្សមានចំនួន ៤១០នាក់ ស្រីចំនួន ១៦៣នាក់ អ្នកអាណាព្យាបាលមានចំនួន ៩២នាក់ ស្រីចំនួន ៥៤នាក់ គណៈគ្រប់គ្រងសាលាមានចំនួន ១៨នាក់ ស្រីចំនួន ០នាក់ មន្ទីរអប់រំ យុវជន និងកីឡា និងការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង/ស្រុក/ខណ្ឌមានចំនួន ១៣នាក់ ស្រីចំនួន ០នាក់ និងគ្រូបណ្តុះបណ្តាលជំនាញមានចំនួន ២០នាក់ ស្រី ០នាក់។

### ៣.២. ការសាងឧបករណ៍ប្រមូលព័ត៌មាន

កម្រងសំណួរដែលត្រូវបានប្រើប្រាស់ក្នុងការសិក្សាស្រាវជ្រាវនេះ គឺជាការដកស្រង់ និងកែសម្រួលខ្លឹមសារឱ្យសមស្របទៅនឹងបរិបទនៃការសិក្សាស្រាវជ្រាវពីអ្នកស្រាវជ្រាវ។ កម្រងសំណួរក្រុមគោលដៅ ត្រូវបានដកស្រង់ និងកែសម្រួលចេញពីនាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ (២០២១)។

### ៣.៣. ដំណើរការប្រមូលព័ត៌មាន

កម្រងសំណួរប្រមូលព័ត៌មានត្រូវបានធ្វើសម្ភាសន៍ដោយផ្ទាល់ជាមួយសំណាកនៅតាមសាលារៀនគោលដៅ ចាប់ផ្តើមពីថ្ងៃទី១៨ ខែកក្កដា រហូតដល់ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២៤។

### ៣.៤. ការវិភាគទិន្នន័យ

មុននឹងឈានដល់ការវិភាគលទ្ធផលស្រាវជ្រាវ ទិន្នន័យដែលប្រមូលបានតាមរយៈទម្រង់ Google Form ត្រូវបានទាញបញ្ចូលក្នុងកម្មវិធី Microsoft Excel 2013 ដើម្បីសម្អាតទិន្នន័យជំហានដំបូង និងកែក្បាលតារាងឱ្យត្រូវគ្នាទៅនឹងទម្រង់កម្មវិធីវិភាគដែលត្រូវបានរៀបចំទុកជាមុន។ បន្ទាប់មក អ្នកសិក្សាស្រាវជ្រាវ បានយកទិន្នន័យទាំងអស់ដែលប្រមូលបានពីក្នុងទម្រង់ Ms.Excel ទៅក្នុងកម្មវិធីវិភាគស្ថិតិ និងធ្វើការវិភាគរកលទ្ធផលផ្អែកលើសំណួរស្រាវជ្រាវ និងតម្រូវការជាក់ស្តែង។

ទិន្នន័យដែលទទួលបាន នឹងត្រូវប្រើប្រាស់ការវិភាគតាមវិធីស្ថិតិច្បាស់លាស់ ដើម្បីទាញបានតម្លៃសន្និដ្ឋានមួយជាក់លាក់ឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវ។ ក្នុងការឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវខាងលើ អ្នកស្រាវជ្រាវបានប្រើប្រាស់កម្មវិធីវិភាគស្ថិតិ៖ ស្ថិតិពណ៌នា (Descriptive Statistics) ដើម្បីរកតម្លៃមធ្យមគិតជាភាគរយ និងគម្លាតស្តង់ដា មកវិភាគសិក្សាប្រៀបធៀបពីភាពប្រែប្រួលផ្អែកស្ថិតិរវាងក្រុមអថេរ។

# ៤. លទ្ធផលស្រាវជ្រាវ

## ៤.១. ការវិភាគទិន្នន័យប្រជាសាស្ត្រ

### ៤.១.១. ទិន្នន័យប្រជាសាស្ត្ររបស់សិស្ស

តារាងទី១ ខាងក្រោមបង្ហាញថា ការសិក្សាស្រាវជ្រាវនេះ មានសិស្សចំណេះទូទៅដែលកំពុងសិក្សាចាប់ពីថ្នាក់ទី១០ ដល់ថ្នាក់ទី១២ និងសិស្សអប់រំបច្ចេកទេស ថ្នាក់ឆ្នាំទី១ ទី២ និងថ្នាក់ឆ្នាំទី៣ ចូលរួមឆ្លើយកម្រងសំណួរចំនួន ៤១០នាក់ ស្រី ២៤៧នាក់ ដែលក្នុងនោះសិស្សដែលកំពុងរៀននៅបណ្តុំថ្នាក់វិទ្យាសាស្ត្រមានចំនួន ២២៨នាក់ ស្មើនឹង ៥៥.៦% នៃសិស្សសរុប។ សិស្សដែលកំពុងរៀននៅបណ្តុំថ្នាក់វិទ្យាសាស្ត្រសង្គមមានចំនួន ១៦៩នាក់ ស្មើនឹង ៤១.២% នៃសិស្សសរុប ខណៈអ្នកចូលរួមឆ្លើយកម្រងសំណួរ ១៣នាក់ស្មើនឹង ៣.២% ផ្សេងទៀត ជាក្រុមសិស្សដែលកំពុងរៀននៅបណ្តុំថ្នាក់អប់រំបច្ចេកទេស។ សិស្សចំណេះទូទៅថ្នាក់ទី១០ និងសិស្សអប់រំបច្ចេកទេស ថ្នាក់ឆ្នាំទី១ ចំនួន ១៨នាក់ ស្មើនឹង ៤.% នៃសិស្សសរុប សិស្សចំណេះទូទៅថ្នាក់ទី១១ និងសិស្សអប់រំបច្ចេកទេស ថ្នាក់ឆ្នាំទី២ ចំនួន ២១១នាក់ ស្មើនឹង ៥១.៥% នៃសិស្សសរុប និងសិស្សចំណេះទូទៅថ្នាក់ទី១២ និងសិស្សអប់រំបច្ចេកទេស ថ្នាក់ឆ្នាំទី៣ ចំនួន ១៨១នាក់ស្មើនឹង ៤៤.១% នៃសិស្សសរុប។

តារាងដដែលនេះ បង្ហាញថាសិស្សចូលរួមឆ្លើយកម្រងសំណួរទាំងអស់ខាងលើនេះ ជាសិស្សនៃវិទ្យាល័យធនធានចំនួន ៨ នៃរាជធានីខេត្តទាំង ៨ ក្នុងប្រទេសកម្ពុជា។ ក្នុងនោះ សិស្សនៃវិទ្យាល័យអង្គរខេត្តសៀមរាប បានចូលរួមឆ្លើយកម្រងសំណួរច្រើនជាងគេរហូតដល់ ៧៨នាក់ ស្មើនឹង ១៩.០% ខណៈសិស្ស មកពីវិទ្យាល័យសម្តេចឪ សម្តេចម៉ែ ខេត្តរតនគិរី បានចូលរួមឆ្លើយកម្រងសំណួរច្រើនជាង តិចជាងគេមាន ២៥នាក់ ស្មើនឹង ៦.១%។

តារាងដដែលនេះ បង្ហាញថាស្ថានភាពគ្រួសាររបស់សិស្សមាន សិស្សក្រីក្រចំនួន ៥៧នាក់ ស្មើនឹង ១៣.៩% សិស្សមធ្យមចំនួន ៣៤០នាក់ ស្មើនឹង ៨២.៩% និងសិស្សធូរធារចំនួន ១៣នាក់ ស្មើនឹង ៣.២% ។ សិស្សមានពិការភាពចំនួន ១នាក់ ក្នុងចំណោមសិស្សសរុប ៤១០នាក់។

*តារាងទី ១ ទិន្នន័យប្រជាសាស្ត្ររបស់សិស្ស (n = 410)*

| ព័ត៌មានទូទៅ | | ចំនួន | ភាគរយ |
|---|---|---|---|
| **ភេទ** | | | |
| | ស្រី | 163 | 39.8 |
| | ប្រុស | 247 | 60.2 |
| | **សរុប** | **410** | **100** |
| **បណ្តុំថ្នាក់** | | | |
| | វិទ្យាសាស្ត្រ | 228 | 55.6 |

| | | | |
|---|---|---|---|
| | វិទ្យាសាស្ត្រសង្គម | 169 | 41.2 |
| | ជំនាញបច្ចេកទេស | 13 | 3.2 |
| | **សរុប** | **410** | **100** |
| **កម្រិតថ្នាក់រៀន** | | | |
| | ថ្នាក់ទី១០/ឆ្នាំទី១ | 18 | 4.4 |
| | ថ្នាក់ទី១១/ឆ្នាំទី២ | 211 | 51.5 |
| | ថ្នាក់ទី១២/ឆ្នាំទី៣ | 181 | 44.1 |
| | **សរុប** | **410** | **100** |
| **របាយសិស្សតាមវិទ្យាល័យ** | | | |
| | វិ.ស្វាយរៀង | 56 | 13.7 |
| | វិ.ហ៊ុនសែន កំពង់ពពិល | 51 | 12.4 |
| | វិ.ហ៊ុនសែន មណ្ឌលគិរី | 56 | 13.7 |
| | វិ.ពោធិ៍សាត់ | 51 | 12.4 |
| | វិ.ហ៊ុន សែន សុម្ភ:បុរ: | 47 | 11.5 |
| | វិ.អង្គរ | 78 | 19.0 |
| | វិ.សម្តេចឪ សម្តេចម៉ែ | 25 | 6.1 |
| | វិ.នេត យ៉ង់ | 46 | 11.2 |
| | **សរុប** | **410** | **100** |
| **រាជធានីខេត្ត** | | | |
| | ស្វាយរៀង | 56 | 13.7 |
| | ព្រៃវែង | 51 | 12.4 |
| | មណ្ឌលគិរី | 56 | 13.7 |
| | ពោធិ៍សាត់ | 51 | 12.4 |
| | ក្រចេះ | 47 | 11.5 |

| | | | |
|---|---|---|---|
| | សៀមរាប | 78 | 19.0 |
| | រតនគិរី | 25 | 6.1 |
| | បាត់ដំបង | 46 | 11.2 |
| | **សរុប** | **410** | **100** |
| **ស្ថានភាពគ្រួសាររបស់សិស្ស** | | | |
| | ក្រីក្រ | 57 | 13.9 |
| | មធ្យម | 340 | 82.9 |
| | ធូរធារ | 13 | 3.2 |
| | **សរុប** | **410** | **100** |
| **ពិការភាពរបស់សិស្ស** | | | |
| | កាយសម្បទាគ្រប់គ្រាន់ | 409 | 99.8 |
| | កាយសម្បទាមិនគ្រប់គ្រាន់ | 1 | 0.2 |
| | **សរុប** | **410** | **100** |

### ៤.១.២. ទិន្នន័យប្រជាសាស្ត្ររបស់អ្នកអាណាព្យាបាល

តារាងទី២ ខាងក្រោមបង្ហាញថា ការសិក្សាស្រាវជ្រាវនេះ មានអ្នកអាណាព្យាបាល ចូលរួមឆ្លើយកម្រងសំណួរចំនួន ៩២នាក់ ស្រី ៥៤នាក់ ស្មើនឹង ៤១.៣%។ អ្នកអាណាព្យាបាល មានក្រុមអាយុចន្លោះ ៣០-៣៩ឆ្នាំ មានចំនួន ២៣នាក់ ស្មើនឹង ២៥.០% ក្រុមអាយុចន្លោះ៤០-៤៩ឆ្នាំ មានចំនួន ៥០នាក់ ស្មើនឹង ៥៤.៣% និងតាមដោយក្រុមអាយុចាប់ពី៥០ឆ្នាំឡើងចំនួន ១៩នាក់ ស្មើនឹង ២០.៧%។

តារាងដដែលនេះ បង្ហាញថាស្ថានភាពគ្រួសាររបស់អ្នកអាណាព្យាបាល ដែលមានជីវភាពក្រីក្រចំនួន២០នាក់ ស្មើនឹង២១% មធ្យមចំនួន៧២នាក់ ស្មើនឹង៧៨.៣ និងធូរធារ០០នាក់

តារាង៤ដដែល បានបង្ហាញអំពីប្រភេទមុខរបរ០៥ប្រភេទផ្សេងគ្នានៃអ្នកអាណាព្យាបាល ចូលរួមឆ្លើយកម្រងសំណួររៀបតាមលំដាប់ពីច្រើន ទៅតិច ជាអាទិ៍៖ កសិករចំនួន៤៥នាក់ ស្មើនឹង៤៨.៩% មេផ្ទះចំនួន១៨នាក់ ស្មើនឹង១៩.៦% អាជីវករចំនួន១៦នាក់ ស្មើនឹង១៧.៤% មន្ត្រីរាជការចំនួន១១នាក់ ស្មើនឹង១២% និងតិចជាងគេជាកម្មករចំនួន០២នាក់ ស្មើនឹង២.២%។

ព័ត៌មានចុងក្រោយគេ តារាងខាងក្រោមបង្ហាញពីទីលំនៅអ្នកអាណាព្យាបាល តាមរាជធានី/ខេត្ត ដែលមានពីចំនួនច្រើន ទៅតិច ជាអាទិ៍៖ពោធិ៍សាត់ចំនួន៣៥នាក់ ស្មើនឹង៣៨% ស្វាយរៀងចំនួន១៨នាក់ ស្មើនឹង១៩.៦% រតនៈគិរី ចំនួន១៧នាក់ ស្មើនឹង១៨.៥% សៀមរាប ចំនួន១០នាក់ ស្មើនឹង១០.៩% និង តិចជាងគេ គឺកំពង់ធំ ចំនួន០៦នាក់ ស្មើនឹង៦.៥% ព្រៃវែង ចំនួន០៦នាក់ ស្មើនឹង៦.៥%។

*តារាងទី ២ ទិន្នន័យប្រជាសាស្ត្រអ្នកអាណាព្យាបាល (N = 92)*

| ព័ត៌មានទូទៅ | | ចំនួន | ភាគរយ |
|---|---|---|---|
| ភេទ | | | |
| | ស្រី | 54 | 41.3 |
| | ប្រុស | 38 | 58.7 |
| | **សរុប** | **92** | **100** |
| ក្រុមអាយុ | | | |
| | ៣០-៣៩ឆ្នាំ | 23 | 25.0 |
| | ៤០-៤៩ឆ្នាំ | 50 | 54.3 |
| | ចាប់ពី៥០ឆ្នាំឡើង | 19 | 20.7 |
| | **សរុប** | **92** | **100** |
| ស្ថានភាពគ្រួសាររបស់អ្នកអាណាព្យាបាល | | | |
| | ក្រីក្រ | 20 | 21 |
| | មធ្យម | 72 | 78.3 |
| | ធូរធារ | 0 | 0 |
| | **សរុប** | **92** | **100** |
| មុខរបរបច្ចុប្បន្ន | | | |
| | កសិករ | 45 | 48.9 |
| | មេផ្ទះ | 18 | 19.6 |
| | អាជីវករ | 16 | 17.4 |
| | កម្មករ | 2 | 2.2 |

| | | |
|---|---|---|
| មន្ត្រីរាជការ | 11 | 12 |
| **សរុប** | **92** | **100** |
| **ទីលំនៅបច្ចុប្បន្នរាជធានី/ខេត្ត** | | |
| ស្វាយរៀង | 18 | 19.6 |
| កំពង់ធំ | 6 | 6.5 |
| ព្រៃវែង | 6 | 6.5 |
| ពោធិ៍សាត់ | 35 | 38 |
| សៀមរាប | 10 | 10.9 |
| រតនៈគិរី | 17 | 18.5 |
| **សរុប** | **92** | **100** |

### ៤.១.៣. ទិន្នន័យប្រជាសាស្ត្រគណៈគ្រប់គ្រងសាលា

តារាងទី៣ ខាងក្រោមបង្ហាញថា ការសិក្សាស្រាវជ្រាវនេះ មានគណៈគ្រប់គ្រងសាលាចំនួន១៨នាក់ ស្រី០០នាក់ ចូលរួមឆ្លើយកម្រងសំណួរ។ របាយគណៈគ្រប់គ្រងសាលាចំនួនចាប់ពី០១នាក់ ទៅ០៣នាក់ ជាអាទិ៍៖ វិទ្យាល័យអង្គរ ចំនួន០៣នាក់ ស្មើនឹង១៦.៧% វិទ្យាល័យ សម្តេចឪ សម្តេចម៉ែ ចំនួន០៣នាក់ ស្មើនឹង១៦.៧% វិទ្យាល័យ នេត យ៉ង់ ចំនួន០៣នាក់ ស្មើនឹង១៦.៧% វិទ្យាល័យស្វាយរៀង ចំនួន០២នាក់ ស្មើនឹង១១.១% វិទ្យាល័យ ហ៊ុន សែនកំពង់ពពិល ចំនួន០២នាក់ ស្មើនឹង១១.១% វិទ្យាល័យហ៊ុន សែនមណ្ឌលគិរី ចំនួន០២នាក់ ស្មើនឹង១១.១% វិទ្យាល័យពោធិ៍សាត់ ចំនួន០២នាក់ ស្មើនឹង១១.១% វិទ្យាល័យហ៊ុន សែន សុម្ភៈបុរៈ ចំនួន០១នាក់ ស្មើនឹង៥.៦%។

តារាងដដែលនេះ បង្ហាញរបាយគណៈគ្រប់គ្រងសាលាសរុបចំនួន០៨ខេត្ត ជាអាទិ៍៖ សៀមរាប ចំនួន០៣នាក់ ស្មើនឹង១៦.៧% រតនៈគិរី ចំនួន០៣នាក់ស្មើនឹង១៦.៧% បាត់ដំបង ចំនួន០៣នាក់ស្មើនឹង១៦.៧% ស្វាយរៀង ចំនួន០២នាក់ ស្មើនឹង១១.១% ព្រៃវែង ចំនួន០២នាក់ ស្មើនឹង១១.១% មណ្ឌលគិរី ចំនួន០២នាក់ ស្មើនឹង១១.១% ពោធិ៍សាត់ ចំនួន០២នាក់ ស្មើនឹង១១.១% និងក្រចេះ ចំនួន០១នាក់ ស្មើនឹង៥.៦%។

*តារាងទី ១ ទិន្នន័យប្រជាសាស្ត្ររបស់គណៈគ្រប់គ្រងសាលា (n = 18)*

| ព័ត៌មានទូទៅ | ចំនួន | ភាគរយ |
|---|---|---|
| **ភេទ** | | |
| ស្រី | 18 | 100 |

| | | | |
|---|---|---|---|
| | ប្រុស | 0 | 0 |
| | **សរុប** | **18** | **100** |
| **របាយសិស្សតាមវិទ្យាល័យ** | | | |
| | វិ.ស្វាយរៀង | 2 | 11.1 |
| | វិ.ហ៊ុនសែន កំពង់ពពិល | 2 | 11.1 |
| | វិ.ហ៊ុនសែន មណ្ឌលគិរី | 2 | 11.1 |
| | វិ.ពោធិ៍សាត់ | 2 | 11.1 |
| | វិ.ហ៊ុន សែន សុម្ភៈបុរៈ | 1 | 5.6 |
| | វិ.អង្គរ | 3 | 16.7 |
| | វិ.សម្តេចឳ សម្តេចម៉ែ | 3 | 16.7 |
| | វិ.នេត យ៉ង់ | 3 | 16.7 |
| | **សរុប** | **18** | **100** |
| **រាជធានីខេត្ត** | | | |
| | ស្វាយរៀង | 2 | 11.1 |
| | ព្រៃវែង | 2 | 11.1 |
| | មណ្ឌលគិរី | 2 | 11.1 |
| | ពោធិ៍សាត់ | 2 | 11.1 |
| | ក្រចេះ | 1 | 5.6 |
| | សៀមរាប | 3 | 16.7 |
| | រតនគិរី | 3 | 16.7 |
| | បាត់ដំបង | 3 | 16.7 |
| | **សរុប** | **18** | **100** |

### ៤.១.៤. ទិន្នន័យប្រជាសាស្ត្រមន្ទីរអប់រំ យុវជន និងកីឡា និងការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង/ស្រុក/ខណ្ឌ

តារាងទី៤ ខាងក្រោមបង្ហាញថា ការសិក្សាស្រាវជ្រាវនេះ មានមន្ទីរអប់រំ យុវជន និងកីឡា និងការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង/ស្រុក/ខណ្ឌ ចូលរួមឆ្លើយកម្រងសំណួរចំនួន ១៣ នាក់ ស្រី ០០នាក់។ របាយមន្ទីរអប់រំ យុវជន និងកីឡា និងការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាល ជាអាទិ៍៖ ខេត្តស្វាយរៀង ចំនួន០២នាក់ ស្មើនឹង១៥.៤% ខេត្តព្រៃវែង ចំនួន០២នាក់ ស្មើនឹង ១៥.៤% ខេត្តមណ្ឌលគិរី ចំនួន០២នាក់ ស្មើនឹង១៥.៤% ខេត្តក្រចេះ ចំនួន០១នាក់ ស្មើនឹង ៧.៧% ខេត្តសៀមរាប ចំនួន០២នាក់ ស្មើនឹង១៥.៤% ខេត្តរតនគិរី ចំនួន០១នាក់ ស្មើនឹង ៧.៧% និងខេត្តបាត់ដំបង ចំនួន០១នាក់ ស្មើនឹង ៧.៧%។

*តារាងទី ៤ ទិន្នន័យប្រជាសាស្ត្ររបស់មន្ទីរអប់រំ យុវជន និងកីឡា និងការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង/ស្រុក/ខណ្ឌ (n = 13)*

| ព័ត៌មានទូទៅ | | ចំនួន | ភាគរយ |
|---|---|---|---|
| **ភេទ** | | | |
| | ស្រី | 0 | 0 |
| | ប្រុស | 13 | 100 |
| | **សរុប** | **13** | **100** |
| **របាយមន្ទីរអប់រំ យុវជន និងកីឡា និងការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង/ស្រុក/ខណ្ឌ** | | | |
| | ស្វាយរៀង | 2 | 15.4 |
| | ព្រៃវែង | 2 | 15.4 |
| | មណ្ឌលគិរី | 2 | 15.4 |
| | ពោធិ៍សាត់ | 2 | 15.4 |
| | ក្រចេះ | 1 | 7.7 |
| | សៀមរាប | 2 | 15.4 |
| | រតនគិរី | 1 | 7.7 |
| | បាត់ដំបង | 1 | 7.7 |
| | **សរុប** | **13** | **100** |

#### ៤.១.៥. ទិន្នន័យប្រជាសាស្ត្រគ្រូបណ្តុះបណ្តាលជំនាញ

តារាងទី៥ ខាងក្រោមបង្ហាញថា ការសិក្សាស្រាវជ្រាវនេះ គ្រូបណ្តុះបណ្តាលជំនាញចូលរួមឆ្លើយកម្រងសំណួរចំនួន ២០នាក់ ស្រី ០០នាក់។ របាយបណ្តុះបណ្តាលជំនាញ ជាអាទិ៍៖ ខេត្តស្វាយរៀង ចំនួន ០៣នាក់ ស្មើនឹង១៥% ខេត្តព្រៃវែង ចំនួន០៣នាក់ ស្មើនឹង១៥% ខេត្តមណ្ឌលគិរី ចំនួន០៣នាក់ ស្មើនឹង ១៥% ខេត្តក្រចេះ ចំនួន០២នាក់ ស្មើនឹង១០% ខេត្តសៀមរាប ចំនួន០២នាក់ ស្មើនឹង១០% ខេត្តរតនគិរី ចំនួន០២នាក់ ស្មើនឹង១០% និងខេត្តបាត់ដំបង ចំនួន០២នាក់ ស្មើនឹង១០%។

*តារាងទី ៥ ទិន្នន័យប្រជាសាស្ត្ររបស់គ្រូបណ្តុះបណ្តាលជំនាញ (n = 20)*

| ព័ត៌មានទូទៅ | | ចំនួន | ភាគរយ |
|---|---|---|---|
| **ភេទ** | | | |
| | ស្រី | 0 | 0 |
| | ប្រុស | 20 | 100 |
| | **សរុប** | **20** | **100** |
| **របាយគ្រូបណ្តុះបណ្តាលជំនាញ** | | | |
| | ស្វាយរៀង | 3 | 15 |
| | ព្រៃវែង | 3 | 15 |
| | មណ្ឌលគិរី | 3 | 15 |
| | ពោធិ៍សាត់ | 3 | 15 |
| | ក្រចេះ | 2 | 10 |
| | សៀមរាប | 2 | 10 |
| | រតនគិរី | 2 | 10 |
| | បាត់ដំបង | 2 | 10 |
| | **សរុប** | **20** | **100** |

### ៤.២. លទ្ធផលស្រាវជ្រាវបែបបរិមាណវិស័យ

#### ៤.២.១. សំណួរស្រាវជ្រាវទី១

សំណួរស្រាវជ្រាវទី១៖ តើការតម្រង់ទិសការបណ្តុះបណ្តាលជំនាញមានលក្ខណៈដូចម្តេចខ្លះ?

១.ក. តើសិស្សានុសិស្សយល់ឃើញពីការតម្រង់ទិសការបណ្តុះបណ្តាលជំនាញមានលក្ខណៈដូចម្តេចខ្លះ?

តាមតារាងទី៦ ខាងក្រោមនេះ យើងអាចពិនិត្យមើលលើលំដាប់ (ពីខ្ពស់ទៅទាប) សិស្សានុសិស្សបានផ្តល់ចំណាត់ថ្នាក់នៃប្រសិទ្ធភាព ក្នុងការតម្រង់ទិសការបណ្តុះបណ្តាលជំនាញរបស់សាលារៀនពួកគេៈ ៦)ការដាក់ពាក្យស្នើសុំចូលរៀនជំនាញដោយស្ម័គ្រចិត្តនិងមិនមានការបង្ខិតបង្ខំ មានតម្លៃមធ្យម ៤.៨ និងគម្លាតស្តង់ដា ០.៥២ , ៣)សាលារៀនបានជួយជំរុញ លើកទឹកចិត្ត និងផ្តល់ឱកាសឱ្យសិស្សដាក់ពាក្យចូលរៀនជំនាញ មានតម្លៃមធ្យម ៤.៧ និងគម្លាតស្តង់ដា ០.៥៩ , ៤)អ្នកអាណាព្យាបានជួយជំរុញ លើកទឹកចិត្ត ឯកភាពយល់ព្រម និងផ្តល់ឱកាសឱ្យប្អូនបានចូលរៀនជំនាញ មានតម្លៃមធ្យម ៤.៤៩ និងគម្លាតស្តង់ដា ០.៧៦ , ៥)អ្នកអាណាព្យាបាល បានជួយជំរុញ លើកទឹកចិត្ត ឯកភាពយល់ព្រម និងផ្តល់ឱកាសឱ្យប្អូនបានចូលរៀនជំនាញ មានតម្លៃមធ្យម ៤.៤៨ និងគម្លាតស្តង់ដា ០.៧៧ , ១)ការផ្សព្វផ្សាយព័ត៌មានស្តីពីការបណ្តុះបណ្តាលជំនាញបន្ថែមផ្នែកស្នែម មានតម្លៃមធ្យម ៤.២ និងគម្លាតស្តង់ដា ០.៩២ និង ២) សាលារៀនបានផ្សព្វផ្សាយពីលទ្ធផលដែលបានមកពីការសិក្សាវាស់ស្ទង់ជំនាញសម្រាប់ធ្វើការបណ្តុះបណ្តាលដល់សិស្ស មានតម្លៃមធ្យម ៤.១២ និងគម្លាតស្តង់ដា ០.៨៨។

*តារាងទី ៦ ស្ថានភាពសិស្សទទួលការតម្រង់ទិសការបណ្តុះបណ្តាលជំនាញ (n = 410)*

| កូដសកម្មភាព | ការតម្រង់ទិសការបណ្តុះបណ្តាលជំនាញ | តម្លៃមធ្យម | គំ.ស្តង់ដា | លំដាប់ |
|---|---|---|---|---|
| ១ | ការផ្សព្វផ្សាយព័ត៌មានស្តីពីការបណ្តុះបណ្តាលជំនាញបន្ថែមផ្នែកស្នែម | 4.2 | 0.92 | 5 |
| ២ | សាលារៀនបានផ្សព្វផ្សាយពីលទ្ធផលដែលបានមកពីការសិក្សាស្ទង់ជំនាញសម្រាប់ធ្វើការបណ្តុះបណ្តាលដល់សិស្ស | 4.12 | 0.88 | 6 |
| ៣ | សាលារៀនបានជួយជំរុញ លើកទឹកចិត្ត និងផ្តល់ឱកាសឱ្យសិស្សដាក់ពាក្យចូលរៀនជំនាញ | 4.7 | 0.59 | 2 |
| ៤ | អ្នកអាណាព្យាបានជួយជំរុញ លើកទឹកចិត្ត ឯកភាពយល់ព្រម និងផ្តល់ឱកាសឱ្យប្អូនបានចូលរៀនជំនាញ | 4.49 | 0.76 | 3 |
| ៥ | ជំនាញដែលប្អូនជ្រើសរើសបណ្តុះបណ្តាលត្រូវនឹងចំណង់ចំណូលចិត្ត និងការស្រឡាញ់របស់ខ្លួន | 4.48 | 0.77 | 4 |
| ៦ | ការដាក់ពាក្យស្នើសុំចូលរៀនជំនាញដោយស្ម័គ្រចិត្តនិងមិនមានការបង្ខិតបង្ខំ | 4.8 | 0.52 | 1 |

១.ខ. តើអ្នកអាណាព្យាបាលយល់ឃើញពីការតម្រង់ទិសការបណ្តុះបណ្តាលជំនាញមានលក្ខណៈដូចម្តេចខ្លះ?

តាមតារាងទី៧ ខាងក្រោមនេះ យើងអាចពិនិត្យមើលលើលំដាប់ (ពីខ្ពស់ទៅទាប) អ្នកអាណាព្យាបាលបានផ្តល់ចំណាត់ថ្នាក់នៃប្រសិទ្ធភាព ក្នុងការតម្រង់ទិសការបណ្តុះបណ្តាលជំនាញរបស់សាលារៀនពួកគេៈ ៦)ការដាក់ពាក្យស្នើសុំចូលរៀនជំនាញដោយស្ម័គ្រចិត្ត និងមិនមានការបង្ខិតបង្ខំ មានតម្លៃមធ្យម ៤.៤៥ និងគម្លាតស្តង់ដា ១.០៩ , ៤)អ្នកអាណាព្យាបាល បានជួយជំរុញ លើកទឹកចិត្ត ឯកភាព

យល់ព្រម និងផ្ដល់ឱកាសឱ្យប្អូនបានចូលរៀនជំនាញ មានតម្លៃមធ្យម ៤.៣២ និងគម្លាតស្តង់ដា ១.០៨ , ៣)សាលារៀនបានជួយជំរុញ លើកទឹកចិត្ត និងផ្ដល់ឱកាសឱ្យសិស្សដាក់ពាក្យចូលរៀនជំនាញ មានតម្លៃមធ្យម ៤.២៩ និងគម្លាតស្តង់ដា ១.១១ , ៥)អ្នកអាណាព្យាបាល បានជួយជំរុញ លើកទឹកចិត្ត ឯកភាព យល់ព្រម និងផ្ដល់ឱកាសឱ្យប្អូនបានចូលរៀនជំនាញ មានតម្លៃមធ្យម ៤.២៥ និងគម្លាតស្តង់ដា ១.១៦ , ១)ការផ្សព្វផ្សាយព័ត៌មានស្ដីពីការបណ្ដុះបណ្ដាលជំនាញបន្ថែមផ្នែកស្វែម មានតម្លៃមធ្យម ៣.៨៦ និងគម្លាតស្តង់ដា ០.៩២ និង ២)សាលារៀនបានផ្សព្វផ្សាយពីលទ្ធផលដែលបានមកពីការសិក្សាវាស់ស្ទង់ជំនាញសម្រាប់ធ្វើការបណ្ដុះបណ្ដាលដល់សិស្ស មានតម្លៃមធ្យម ៣.៨ និងគម្លាតស្តង់ដា ១.១៩។

*តារាងទី ២ ស្ថានភាពអ្នកអាណាព្យាបាលទទួលការតម្រង់ទិសការបណ្ដុះបណ្ដាលជំនាញ(n = 92)*

| កូដ សកម្មភាព | ការតម្រង់ទិសការបណ្ដុះបណ្ដាលជំនាញ | តម្លៃមធ្យម | គំ.ស្តង់ដា | លំដាប់ |
|---|---|---|---|---|
| ១ | ការផ្សព្វផ្សាយព័ត៌មានស្ដីពីការបណ្ដុះបណ្ដាលជំនាញបន្ថែមផ្នែកស្វែម | 3.86 | 0.92 | 5 |
| ២ | សាលារៀនបានផ្សព្វផ្សាយពីលទ្ធផលដែលបានមកពីការសិក្សាវាស់ស្ទង់ជំនាញសម្រាប់ធ្វើការបណ្ដុះបណ្ដាលដល់សិស្ស | 3.8 | 1.19 | 6 |
| ៣ | សាលារៀនបានជួយជំរុញ លើកទឹកចិត្ត និងផ្ដល់ឱកាសឱ្យសិស្សដាក់ពាក្យចូលរៀនជំនាញ | 4.29 | 1.11 | 3 |
| ៤ | អ្នកអាណាព្យាបាល បានជួយជំរុញ លើកទឹកចិត្ត ឯកភាព យល់ព្រម និងផ្ដល់ឱកាសឱ្យប្អូនបានចូលរៀនជំនាញ | 4.32 | 1.08 | 2 |
| ៥ | ជំនាញដែលប្អូនជ្រើសរើសបណ្ដុះបណ្ដាលត្រូវនឹងចំណង់ចំណូលចិត្ត និងការស្រឡាញ់របស់ខ្លួន | 4.25 | 1.16 | 4 |
| ៦ | ការដាក់ពាក្យស្នើសុំចូលរៀនជំនាញដោយស្ម័គ្រចិត្តនិងមិនមានការបង្ខិតបង្ខំ | 4.45 | 1.09 | 1 |

១.គ. តើគណៈគ្រប់គ្រងសាលាយល់ឃើញពីការតម្រង់ទិសការបណ្ដុះបណ្ដាលជំនាញមានលក្ខណៈដូចម្ដេចខ្លះ?

តាមតារាងទី៨ ខាងក្រោមនេះ យើងអាចពិនិត្យមើលលើលំដាប់ (ពីខ្ពស់ទៅទាប) គណៈគ្រប់គ្រងសាលាបានផ្ដល់ចំណាត់ថ្នាក់នៃប្រសិទ្ធភាព ក្នុងការតម្រង់ទិសការបណ្ដុះបណ្ដាលជំនាញរបស់សាលារៀនពួកគេៈ ៦)ការដាក់ពាក្យស្នើសុំចូលរៀនជំនាញដោយស្ម័គ្រចិត្ត និងមិនមានការបង្ខិតបង្ខំ មានតម្លៃមធ្យម ៤.៦៧ និងគម្លាតស្តង់ដា០.៦៩,៥)អ្នកអាណាព្យាបាល បានជួយជំរុញ លើកទឹកចិត្ត ឯកភាព យល់ព្រម និងផ្ដល់ឱកាសឱ្យប្អូនបានចូលរៀនជំនាញ មានតម្លៃមធ្យម ៤.៥ និងគម្លាតស្តង់ដា ០.៥១ ,១)ការផ្សព្វផ្សាយព័ត៌មានស្ដីពីការបណ្ដុះបណ្ដាលជំនាញបន្ថែមផ្នែកស្វែម មានតម្លៃមធ្យម ៤.៣៩ និងគម្លាតស្តង់ដា ០.៥ , ២)សាលារៀនបានផ្សព្វផ្សាយពីលទ្ធផលដែលបានមកពីការសិក្សាវាស់ស្ទង់ជំនាញសម្រាប់ធ្វើការបណ្ដុះបណ្ដាលដល់សិស្ស មានតម្លៃមធ្យម ៤.៣៩ និងគម្លាតស្តង់ដា ០.៥ , ៣)សាលារៀនបានជួយជំរុញ លើកទឹកចិត្ត និងផ្ដល់ឱកាសឱ្យសិស្សដាក់ពាក្យចូលរៀនជំនាញ មានតម្លៃមធ្យម ៤.២២ និងគ

ម្លាតស្តង់ដា ០.៦៥ , និង៤)អ្នកអាណាព្យាបាល បានជួយជំរុញ លើកទឹកចិត្ត ឯកភាពយល់ព្រម និងផ្តល់ឱកាសឱ្យប្អូនបានចូលរៀនជំនាញ មានតម្លៃមធ្យម ៤.២២ និងគម្លាតស្តង់ដា ០.៦៥ ។

*តារាងទី ៨ ស្ថានភាពគណៈគ្រប់គ្រងសាលាទទួលការតម្រង់ទិសការបណ្តុះបណ្តាលជំនាញ (n = 18)*

| កូដសកម្មភាព | ការតម្រង់ទិសការបណ្តុះបណ្តាលជំនាញ | តម្លៃមធ្យម | គំ.ស្តង់ដា | លំដាប់ |
|---|---|---|---|---|
| ១ | ការផ្សព្វផ្សាយព័ត៌មានស្តីពីការបណ្តុះបណ្តាលជំនាញបន្ថែមផ្នែកស្វែម | 4.39 | 0.50 | 3 |
| ២ | សាលារៀនបានផ្សព្វផ្សាយពីលទ្ធផលដែលបានមកពីការសិក្សាវាស់ស្ទង់ជំនាញសម្រាប់ធ្វើការបណ្តុះបណ្តាលដល់សិស្ស | 4.39 | 0.50 | 3 |
| ៣ | សាលារៀនបានជួយជំរុញ លើកទឹកចិត្ត និងផ្តល់ឱកាសឱ្យសិស្សដាក់ពាក្យចូលរៀនជំនាញ | 4.22 | 0.65 | 5 |
| ៤ | អ្នកអាណាព្យាបាល បានជួយជំរុញ លើកទឹកចិត្ត ឯកភាពយល់ព្រម និងផ្តល់ឱកាសឱ្យប្អូនបានចូលរៀនជំនាញ | 4.22 | 0.65 | 5 |
| ៥ | ជំនាញដែលប្អូនជ្រើសរើសបណ្តុះបណ្តាលត្រូវនឹងចំណង់ចំណូលចិត្ត និងការស្រឡាញ់របស់ខ្លួន | 4.5 | 0.51 | 2 |
| ៦ | ការដាក់ពាក្យស្នើសុំចូលរៀនជំនាញដោយស្ម័គ្រចិត្តនិងមិនមានការបង្ខិតបង្ខំ | 4.67 | 0.69 | 1 |

១.ឃ. តើមន្ទីរអប់រំ យុវជន និងកីឡា និងការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋាលក្រុង/ស្រុក/ខណ្ឌ យល់ឃើញពីការតម្រង់ទិសការបណ្តុះបណ្តាលជំនាញមានលក្ខណៈដូចម្តេចខ្លះ?

តាមតារាងទី៩ ខាងក្រោមនេះ យើងអាចពិនិត្យមើលលើលំដាប់ (ពីខ្ពស់ទៅទាប) មន្ទីរអប់រំ យុវជន និងកីឡា និងការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋាលក្រុង/ស្រុក/ខណ្ឌ បានផ្តល់ចំណាត់ថ្នាក់នៃប្រសិទ្ធភាព ក្នុងការតម្រង់ទិសការបណ្តុះបណ្តាលជំនាញរបស់សាលារៀនពួកគេ៖ ៥)អ្នកអាណាព្យាបាល បានជួយជំរុញ លើកទឹកចិត្ត ឯកភាពយល់ព្រម និងផ្តល់ឱកាសឱ្យប្អូនបានចូលរៀនជំនាញ មានតម្លៃមធ្យម ៤.៩២ និងគម្លាតស្តង់ដា ០.២៨ , ៦)ការដាក់ពាក្យស្នើសុំចូលរៀនជំនាញដោយស្ម័គ្រចិត្តនិងមិនមានការបង្ខិតបង្ខំ មានតម្លៃមធ្យម ៤.៣៨ និងគម្លាតស្តង់ដា ០.៥១ , ៤)អ្នកអាណាព្យាបាល បានជួយជំរុញ លើកទឹកចិត្ត ឯកភាពយល់ព្រម និងផ្តល់ឱកាសឱ្យប្អូនបានចូលរៀនជំនាញ មានតម្លៃមធ្យម ៣.៩២ និងគម្លាតស្តង់ដា ១.៣៨ , ១)ការផ្សព្វផ្សាយព័ត៌មានស្តីពីការបណ្តុះបណ្តាលជំនាញបន្ថែមផ្នែកស្វែម មានតម្លៃមធ្យម ៣.៨៥ និងគម្លាតស្តង់ដា ០.៦៩ , ២)សាលារៀនបានផ្សព្វផ្សាយពីលទ្ធផលដែលបានមកពីការសិក្សាវាស់ស្ទង់ជំនាញសម្រាប់ធ្វើការបណ្តុះបណ្តាលដល់សិស្ស មានតម្លៃមធ្យម ៣.៦៩ និងគម្លាតស្តង់ដា ០.៤៨ និង៣)សាលារៀនបានជួយជំរុញ លើកទឹកចិត្ត និងផ្តល់ឱកាសឱ្យសិស្សដាក់ពាក្យចូលរៀនជំនាញ មានតម្លៃមធ្យម ៣.៣៨ និងគម្លាតស្តង់ដា ០.៩៦ ។

*តារាងទី ៩ ស្ថានភាពមន្ទីរអប់រំ យុវជន និងកីឡា និងការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋាលក្រុង/ស្រុក/ខណ្ឌទទួលការតម្រង់ទិសការបណ្តុះបណ្តាលជំនាញ (n = 13)*

| កូដសកម្មភាព | ការតម្រង់ទិសការបណ្តុះបណ្តាលជំនាញ | តម្លៃមធ្យម | គំ.ស្តង់ដា | លំដាប់ |
|---|---|---|---|---|
| ១ | ការផ្សព្វផ្សាយព័ត៌មានស្តីពីការបណ្តុះបណ្តាលជំនាញបន្ថែមផ្នែកស្នែម | 3.85 | 0.69 | 4 |
| ២ | សាលារៀនបានផ្សព្វផ្សាយពីលទ្ធផលដែលបានមកពីការសិក្សាវាស់ស្ទង់ជំនាញសម្រាប់ធ្វើការបណ្តុះបណ្តាលដល់សិស្ស | 3.69 | 0.48 | 5 |
| ៣ | សាលារៀនបានជួយជំរុញ លើកទឹកចិត្ត និងផ្តល់ឱកាសឱ្យសិស្សដាក់ពាក្យចូលរៀនជំនាញ | 3.38 | 0.96 | 6 |
| ៤ | អ្នកអាណាព្យាបាល បានជួយជំរុញ លើកទឹកចិត្ត ឯកភាពយល់ព្រម និងផ្តល់ឱកាសឱ្យប្អូនបានចូលរៀនជំនាញ | 3.92 | 1.38 | 3 |
| ៥ | ជំនាញដែលប្អូនជ្រើសរើសបណ្តុះបណ្តាលត្រូវនឹងចំណង់ចំណូលចិត្ត និងការស្រឡាញ់របស់ខ្លួន | 4.92 | 0.28 | 1 |
| ៦ | ការដាក់ពាក្យស្នើសុំចូលរៀនជំនាញដោយស្ម័គ្រចិត្តនិងមិនមានការបង្ខិតបង្ខំ | 4.38 | 0.51 | 2 |

១.ចៈ តើគ្រូបណ្តុះបណ្តាលជំនាញយល់ឃើញពីការតម្រង់ទិសការបណ្តុះបណ្តាលជំនាញមានលក្ខណៈដូចម្តេចខ្លះ?

